# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## ក្រុមប្រឹក្សាធម្មនុញ្ញ

**សំណុំរឿង**

លេខ : ១៤៨/០១១/២០០៨

ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ២០០៨

**សេចក្តីសម្រេច**

លេខ :១០១/០០៦/២០០៨ កបធ.ច

ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ២០០៨

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ១៣ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៦ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ២០០៨ ដែលតម្កល់សេចក្តីសម្រេចរបស់គណៈកម្មការខេត្តកំពង់ធំរៀបចំការបោះឆ្នោត ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ២០០៨
- បានឃើញពាក្យបណ្តឹងរបស់លោក **ឃុន សុផល** និង លោក **សាំង វណ្ណៈ** ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ២០០៨ ប្តឹងមិនសុខចិត្តចំពោះសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត កាលពីថ្ងៃទី ០៦ ខែ សីហា ឆ្នាំ២០០៨ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សា-ធម្មនុញ្ញ បានទទួលនៅថ្ងៃទី ០៨ ខែ សីហា ឆ្នាំ២០០៨ វេលាម៉ោង ១៥:១១ នាទី

- បានឃើញលិខិតដកពាក្យបណ្តឹងចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ២០០៨ របស់លោក **ឃុន សុផល** និង លោក **សាំង វណ្ណៈ** សុំដកពាក្យបណ្តឹងចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ២០០៨ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ១១ ខែ សីហា ឆ្នាំ២០០៨ វេលាម៉ោង ០៩:១៥ នាទី

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**
**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា លិខិតដកពាក្យបណ្តឹងចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ២០០៨ របស់លោក **ឃុន សុផល** និង លោក **សាំង វណ្ណៈ** សុំដកពាក្យបណ្តឹងចុះថ្ងៃទី ០៨ ខែសីហាឆ្នាំ២០០៨ ដែលប្តឹងមិនសុខចិត្តចំពោះសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ២០០៨ បានធ្វើឡើងត្រឹមត្រូវតាមទម្រង់ច្បាប់ ដូច្នេះក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកមកពិនិត្យបាន
- យល់ឃើញថា តាមគោលការណ៍ច្បាប់ ម្ចាស់បណ្តឹងមានសិទ្ធិសុំដកពាក្យបណ្តឹងរបស់ខ្លួនទាំងអស់ ឬមួយផ្នែក បានគ្រប់ពេលវេលាទាំងអស់នៃនីតិវិធី ។

# សម្រេច

**មាត្រា ១.-** ទទួលលិខិតដកពាក្យបណ្តឹងចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ២០០៨ របស់លោក **ឃុន សុផល** និង លោក **សាំង វណ្ណៈ** ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

**មាត្រា ២.-** តម្កល់សេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចុះថ្ងៃទី ០៦ ខែសីហា ឆ្នាំ២០០៨ ដែលតម្កល់សេចក្តីសម្រេចរបស់គណៈកម្មការខេត្តកំពង់ធំរៀបចំការបោះឆ្នោត ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ២០០៨ ទុកជាបានការពេញទាំងមូល ។

**មាត្រា ៣.-** សេចក្តីសម្រេចនេះធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ១៣ ខែសីហា ឆ្នាំ២០០៨ នាពេលប្រជុំពេញអង្គរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ២០០៨

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ឯក សំអុល**